ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..១៧..សរណន

# សារាចរណែនាំ

## ស្តីពី

## ការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុង

## តាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ

អនុលោមតាមសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងប្រកាសលេខ ១១០៩ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ សវនកម្មផ្ទៃក្នុងត្រូវបានបង្កើត និងកំពុងដំណើការ ហើយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនៃក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈក៏ត្រូវបានពង្រីក និងពង្រឹងជាបន្តបន្ទាប់ ។

ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាអ្នកនាំមុខក្នុងវិស័យនេះ បានខិតខំពង្រឹងមូលដ្ឋានច្បាប់ ក៏ដូចជាបច្ចេកទេសជំនាញ ដោយបានចេញផ្សាយនូវបទដ្ឋានគតិយុត្តិ និងរៀបចំជាវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ធ្វើឱ្យគុណភាពការងារសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ បានកើនឡើងមួយកំរិតថែមទៀត ។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលពិនិត្យឃើញថា មុខងារនេះនៅបន្តជួបការលំបាកមួយចំនួនទៀត ពិសេសពាក់ព័ន្ធនឹងថវិកាសំរាប់គាំទ្រសវនកម្ម កិច្ចសហការរវាងអង្គភាពសវនកម្មជាមួយសវនករ ការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង ស្ថាប័ន ការបែងចែកភារកិច្ចរវាងសវនកម្មផ្ទៃក្នុងជាមួយអគ្គាធិការដ្ឋាន/អធិការដ្ឋាន ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងាររបស់សវនកម្មផ្ទៃក្នុង ។

ដោយឡែក រាជរដ្ឋាភិបាលបានណែនាំឱ្យក្រសួង ស្ថាប័ន សិក្សារៀបចំផែនការសកម្មភាពការពារទប់ស្កាត់ និងគ្រប់គ្រងបានប្រកបដោយប្រសិទ្ធភាព នូវហេតុការណ៍អាក្រក់ជាយថាហេតុណាមួយ ដែល

អាចកើតឡើងនៅតាមក្រសួង ស្ថាប័នរដ្ឋ ក៏ដូចនៅតាមទីសាធារណៈ ដែលទីនេះមុខងារសវនកម្មផ្ទៃក្នុង មានតួនាទីគន្លឹះ នៅក្នុងការធានាបាននូវភាពគ្រប់គ្រាន់ ភាពជាក់ស្តែង និងស័ក្តិសិទ្ធិក្នុងការរៀបចំផែនការ សកម្មភាពទាំងនេះ ក៏ដូចជាចំពោះប្រព័ន្ធគ្រប់គ្រងទាំងឡាយដែលត្រូវបង្កើត សំរាប់គាំទ្រដល់ផែនការ សកម្មភាពឱ្យសំរេចបានជោគជ័យ ។

អាស្រ័យហេតុនេះ ដើម្បីជំនះលើការលំបាកដែលសវនកម្មផ្ទៃក្នុងកំពុងជួបប្រទះខាងលើ ជាមួយនឹង គោលបំណងជំរុញឱ្យមុខងារនេះ កាន់តែបំពេញតួនាទីរបស់ខ្លួនបានពេញលេញ ជាពិសេសរួមចំណែកធានា ជោគជ័យជូនដល់កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ២ " **បង្កើនគណនេយ្យភាព ហិរញ្ញវត្ថុ** " ដែលជាសមាសភាពចំបងនៃអភិបាលកិច្ចល្អ និងការពារបាននូវផលវិបាកកើតចេញពីហេតុការណ៍ អាក្រក់ជាយថាហេតុណាមួយ រាជរដ្ឋាភិបាលសូមណែនាំដូចខាងក្រោម ៖

១-ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវបន្តពង្រឹងការអនុវត្តសារាចរណែនាំរបស់ រាជរដ្ឋាភិបាលលេខ ០១ សរណន ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង តាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ។

២-ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវយកចិត្ត ទុកដាក់លើការកសាងផែនការថវិកា និងការបើកផ្តល់ថវិកាជូនសវនករផ្ទៃក្នុងឱ្យបានរលូន និងឆាប់រហ័ស ពិសេសអនុញ្ញាតឱ្យបុរេប្រទានប្រាក់បេសកកម្មដល់ ៥០% នៃថវិកាស្នើសុំចំពោះសវនកម្មផ្ទៃក្នុង ដែលមិនស្ថិត ក្រោមក្រសួង ស្ថាប័នដែលអនុវត្តថវិកាតាមកម្មវិធី ។ ក៏ប៉ុន្តែត្រូវត្រួតពិនិត្យការទូទាត់ឱ្យបានហ្មត់ចត់បំផុត ។

៣-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាអ្នកនាំមុខលើមុខងារសវនកម្មផ្ទៃក្នុង ត្រូវយកចិត្ត ទុកដាក់ពង្រឹងសិទ្ធិអំណាច និងប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង ដោយឡែកត្រូវពិនិត្យលទ្ធភាពកែលំអ ឋានានុក្រមរបស់សវនកម្មផ្ទៃក្នុង ប្រាក់ឧបត្ថម្ភសវនកម្ម និងដោះស្រាយភាពជាន់ភារកិច្ចធ្វារវាងសវនកម្ម ផ្ទៃក្នុងជាមួយអគ្គាធិការដ្ឋាន/អធិការដ្ឋាន ។

៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបន្តកិច្ចការពង្រឹងសមត្ថភាពបច្ចេកទេស មូលដ្ឋានច្បាប់ និង ហេដ្ឋារចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុងផ្សេងៗទៀត សំដៅឱ្យអង្គភាពនេះធានាបាននូវកំរិតជំនាញវិជ្ជាជីវៈខ្ពស់ អាច ជួយដល់ថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈគ្រប់គ្រងបាននូវហានិភ័យ និងចាំបាច់កែ លំអ និងធ្វើបច្ចុប្បន្នភាពលើឯកសារផ្លូវច្បាប់នានា ឱ្យសមស្របនិងមានសង្គតិភាពជាមួយការវិវឌ្ឍន៍ថ្មីៗនៃ ការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងជំនាញសវនកម្មផ្ទៃក្នុង ។

៥-ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវបង្កើនការយកចិត្តទុកដាក់ ចំពោះមុខងារសវនកម្មផ្ទៃក្នុង ។ ដោយឡែកអង្គភាពរងសវនកម្ម ត្រូវសហការផ្តល់ព័ត៌មាន ទិន្នន័យ និង ឯកសារនានាឱ្យបានលឿន និងគ្រប់គ្រាន់ជូនសវនករដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

៦-ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវធានាបង្កើតប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យបានគ្រប់គ្រាន់ ជាក់ស្តែងអនុវត្តបាន មានបច្ចុប្បន្នភាព និងត្រូវបានប្រើប្រាស់ជាប្រចាំ ។ ចំពោះប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលត្រូវប្រើប្រាស់តែក្នុងករណីគ្រោះអាសន្នជាយថាហេតុ ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវធានាភាពស្ទាត់ជំនាញ និងប្រសិទ្ធភាពប្រើប្រាស់ ដោយត្រូវស្វះស្វែងផ្លាស់ប្តូរបទពិសោធន៍ និងធ្វើការហាត់សមសាកល្បងឱ្យបានជាប់ជាប្រចាំ ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈទាំងអស់ ត្រូវយកចិត្តទុកដាក់សហការអនុវត្តឱ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចំលងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ

" ដើម្បីសហការអនុវត្ត "

-ឯកសារ-កាលប្បវត្តិ